{បានទទួលឯកសារនេះ ខែតុលា ឆ្នាំ២០១៩ អ្នកផ្ដល់ឯកសារ សុំមិនបញ្ចេញឈ្មោះ}

# ឈ្មួញឈើដុះស្លែកំរិតខ្ពស់

**High Profile Logging Cartel**

## ភាគ១

## អំពីឧកញ៉ា បណ្ឌិតកិត្តិយសផ្នែកគ្រប់គ្រង ពាណិជ្ជកម្ម និង សេដ្ឋកិច្ច ទ្រី ភាព



**US$1,256,737,230** (មួយពាន់ពីររយហាសិបប្រាំមួយលាន និងប្រាំពីរសែន បីម៉ឺនប្រាំពីរពាន់ ពីររយសាមសិប ដុល្លារសហរដ្ឋ) ត្រូវបានរកឃើញ ពីការបូកសរុបដោយត្រួសៗនូវទំហំទឹកប្រាក់ដែលក្រុមហ៊ុនទ្រី ភាព បានវិនិយោគ និងផ្សព្វផ្សាយ កន្លងមក។ ហើយវាក៏មិនអាចប្រកែកបានឡើយ នូវអ្វីដែលឈ្មួញឈើជាន់ខ្ពស់ដ៏មានឥទ្ធិពលម្នាក់ដែលធ្លាប់ និងកំពុងបន្តរកស៊ីឈើឆ្លងដែន ខ្នាតយក្សលំដាប់អន្តរជាតិមួយនេះ ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋាភិបាល ហើយបានរីកចំរើន រហូតដឹកនាំក្រុមហ៊ុន ចំនួន **២១** ធំៗ ជាបន្តទៀត ដែលបានចុះបញ្ជី និងបង្ហាញជាសាធារណៈ។ ទ្រី ភាព ក៏ទទួលបានដីសម្បទានសេដ្ឋកិច្ច និងដីអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ពីរដ្ឋាភិបាលចំនួន ១៤ ក្រុមហ៊ុន មានផ្ទៃដីសរុប ចំនួន **68,088** ហិកតា ក្នុងនោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២នៅកន្ទុយនាគ នៃឧទ្យានជាតិវីរៈជ័យ ត្រូវបានក្រុមហ៊ុនប្រគល់ជូនរដ្ឋវិញ ដែលមានទំហំជិត២០០០០ហិកតា ដោយក្រុមហ៊ុននេះ បានប្រមូលឈើ រួចរាល់ជាស្ថាពរ និងបានដាំ**ដើមទិព្វ** (ព្រោះមនុស្សមើលមិនឃើញ) ក្រុមហ៊ុនទាំងនោះមាន:

1-M D S HENG HE INVESTMENT CO., LTD., 2-M D S THMORDA S E Z CO., LTD.
3-M. D. S. IMPORT EXPORT CO., LTD. 4-M.D.S GROUP CO., LTD.
5-M.D.S IMPORT EXPORT CO., LTD. 6-PAPA PETROLEUM CO., LTD.
7-TP LUCKY CHAIN HOLDING CO., LTD. 8-TRY PALACE RESORT & SPA CO., LTD.
9-TRY PHEAP APHIWATH CO., LTD. 10-TRY PHEAP DRY PORT CO., LTD.
11-TRY PHEAP ENGINEERING & CONSTRUCTION CO., LTD. 12-TRY PHEAP GROUP CO., LTD.
13-TRY PHEAP IMPORT EXPORT CO., LTD. 14-TRY PHEAP OYADAV S E Z CO., LTD.
15-TRY PHEAP RONGQING MANUFACTURE CO., LTD. 16-TRY PHEAP TRAVEL & TOURS CO., LTD.
17-TRY PHEAP GRAND ROYAL (CAMBODIA) CO., LTD. 18-TRY PHEAP PROPERTY CO., LTD.
19-GLOBAL GREEN (CAMBODIA) ENERGY DEVELOPMENT CO., LTD. គ្រប់គ្រងដោយ កូនប្រុសឈ្មោះ ទ្រី ដាលុច 20-LALUNE OJ TRADING CO., LTD. គ្រប់គ្រងដោយ កូនស្រីឈ្មោះ ទ្រី ដាលីន និងក្រុមហ៊ុន 21-TRY PHEAP LI CHUNBAO CO., LTD. គ្រប់គ្រងដោយ កូនប្រុស ឈ្មោះ ទ្រី ដាភ័ស្ស

# ក្រុមហ៊ុនទទួលបានដីសម្បទានសេដ្ឋកិច្ច និងដីវិនិយោគតំបន់សេដ្ឋកិច្ចពិសេសរបស់ទ្រី ភាពឆ្នាំ ២០១១

| No | Company | Area | Land size in ha | Other |
|---|---|---|---|---|
| 1 | Try Pheap Oyadav S.E.Z | O Yadav, Rattanakiry | 136 | Sub decree No.219/ 7 May 2013 |
| 2 | MDS Thmorda S.E.Z Co., Ltd | Thmorda, Pursat | 2,236 | CDC data |
| 3 | M D S Import Export Co., Ltd | Thmorda, Pursat | 4,200 | Map attached |
| 4 | MDS Thmorda S.E.Z Co., Ltd បានប្រគល់ជូនរដ្ឋវិញ | National park Virakchey in Taveng, Rattanakiry | 9,146 | sub decree No.26/29 Sept 2011 |
| 5 | Try Pheap Import Export Co., Ltd បានប្រគល់ជូនរដ្ឋវិញ | National park Virakchey in Taveng, Rattanakiry | 9,709 | Sub decree No.25/9 Feb/2011 and No.92 20 May 2011 |
| 6 | Try Pheap Import Export Co., Ltd | Beungper, Rovieng, Preah Vihear | 9,916 | Sub decree No.82/19 May 2011 |
| 7 | M.D.S Import Export Co., Ltd | Phnom Samkos, Veal Veng | 4,402 | Sub decree No.92/5 Aug 2010 |
| 8 | M.D.S Import Export Co., Ltd | Botum Sakor, Kohkong | 6,771 | Sub decree No.248/ 12 Dec 2012 |
| 9 | (CAMBODIA) HONG FUTRY PHEAP MINING DEVELOPMENT CONSTRUCTION GROUP CO, LTD (Try Pheap and Vinacomin Joint Venture (Southern Mining).) | Anlong Phe, Anlong Chrey, Thalaborivath, Stungtreng | 6,000 | Area 1 and 2 |
| 10 | Cambodian company Mong Good Luck Mining | Thalaborivath, Stungtreng | 9,000 | Mining concession data |
| 11 | MDS Import Export Co., Ltd | Phnom Samkos, Veal Veng, Pursat | 1970 and 4,402 = 6372 | Sub decree No.176/30.12.2010 and 126___28.09.2010 |
| 12 | Island Tonsay, Kep | Kep | 200 | Report of island concession |

# ការគណនាទំហំទឹកប្រាក់វិនិយោគរបស់ទ្រី ភាព គ្រុប

| លរ | តំបន់ | ទំហំគិតជាការ៉េ | តម្លៃគិតជាការ៉េ | សរុប |
|---|---|---|---|---|
| ១ | ខុនដូនៅ បឹងកេងកង[1] | 1862 | $5,000 | $9,310,000 |
| ២ | ទ្រី ផាឡេស នៅ កែប[2] | 20,000 | $500 | $10,000,000 |
| ៣ | PAPA Petroleum Co., Ltd សហការជាមួយ PTT Global Chemical Plc ប្រទេសថៃ និងចិន[3] | | | $400,000,000 |
| ៤ | កំពង់ផែអន្តរជាតិទឹកឈូ កំពត MoU ជាមួយចិន[4] | | | $300,000,000 |
| ៥ | អាជីវកម្មឈើក្រញូងស្ទឹងអាតៃ[5] | | | $220,000,000 |
| ៦ | សារៈមន្ទីរក្រញូង[6] | | | $5,600,000 |
| ៧ | ដីសារៈមន្ទីរក្រញូង | 450,000 | $100 | $45,000,000 |
| ៨ | ដីសិប្បកម្មនៅសំរោង | 15000 | $50 | $750,000 |
| ៩ | គំរោងសាងសង់សណ្ឋាគារ និងកាស៊ីណូនៅថ្មដា[7] | | | $98,977,230 |
| ១០ | តំបន់សេដ្ឋកិច្ចពិសេស សណ្ឋាគារ និងកាស៊ីណូស្ថានីយសាំង នៅ អូរយ៉ាដាវ[8] | | | $30,800,000 |
| ១១ | ផែស្ងួតនៅឧត្តុង្គ កំពង់ស្ពឺ | 300,000 | $50 | $15,000,000 |
| ១២ | កាស៊ីណូ និងសណ្ឋាគារ ច្រកអានសេះ | 50,000 | $50 | $10,000,000 |

[1] https://www.realestate.com.kh/km/news/boeung-keng-kang-suburb-phnom-penh/
[2] Easy Property Investment
[3] https://www.phnompenhpost.com/business/plans-spilt-oil-refinery
[4] https://www.phnompenhpost.com/business/tycoon-try-pheap-plans-300m-kampot-port
[5] https://www.phnompenhpost.com/national/logging-baron-claims-tree-felling-days-over
[6] https://www.phnompenhpost.com/national/logging-baron-claims-tree-felling-days-over
[7] https://business.khmernote.com/44754
[8] http://jn.khrnews.com/?p=255 របាយការណ៍ ឧកញ៉ា លាង ច័ន្ទមុន្នី ថ្ងៃសម្ពោធ

| | | | | |
|---|---|---|---|---|
| ១៣ | ផលិតម៉ូតូសហាការជាមួយក្រុមហ៊ុន ចិន[9] | | | $50,000,000 |
| ១៤ | ចំការកៅស៊ូ បឹងទន្លេម្រេច 3376 ហាត[10] | | | $52,000,000 |
| ១៥ | ចំការកៅស៊ូនៅថ្មដា និងប្រមោយ វាលវែង ១៨៦០ ហាត[11] | 1,860 | $5,000 | $9,300,000 |
| | សរុប | | | **$1,256,737,230** |

នៅលើឆាកអន្តរជាតិទ្រី ភាព បានចាប់ដៃសហាការវិនិយោគ ជាមួយក្រុមហ៊ុនមកពីប្រទេស ចិន បើកកំពង់ផែអន្តរជាតិនៅទឹកឈូ ខេត្តកំពត ក្រុមហ៊ុនផលិតម៉ូតូ ឡាន សំរាប់នាំចេញ ក្រុមហ៊ុនម៉ាស៊ីនត្រជាក់ ជាដើម។ ទ្រី ភាព ក៏បានសហាការជាមួយក្រុមហ៊ុនមកពីប្រទេសថៃក្នុងការនាំចេញដំឡូងមី និងមានមហិច្ឆិតា សហាការជាមួយក្មួយរបស់ប្រធាធិបតីរុស្សី Ruman Putin ក្នុងការវិនិយោគផលិតថាមពលជាមួយក្រុមហ៊ុន Putin Consulting[12] បន្តទៀត។

តាមគេហទំព័រផ្លូវការរបស់ក្រុមហ៊ុន ទ្រី ភាព គ្រុប បានបង្ហាញអំពីអាជីវកម្មមានដូចជា:

ទ្រី ភាព មានការិយាល័យនៅកណ្ដាលរាជធានីភ្នំពេញ ទល់មុខមន្ទីរពេទ្យព្រះអង្គឌួង ដែលសាងសង់ពីឈើប្រណិត សាងសង់ខុនដូរប្រណិតនៅអតីតដីសាលាកំពូលនៅបឹងកេងកង មានសណ្ឋាគារ និងកាស៊ីណូមិត្តភាពនៅជាប់ព្រំដែនវៀតណាម អូរយ៉ាដាវ សណ្ឋាគារ និងកាស៊ីណូនៅថ្មដា ជាប់ព្រំដែនថៃ សណ្ឋាគារនិង កាស៊ីណូនៅអានសេះ ជាប់ព្រំដែនថៃ នៃស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងរីសត និង ស្ប៉ា នៅកណ្ដាលក្រុងកែប ដ៏ធំសម្បើម ផងដែរ។

ទ្រី ភាព មានចំការកៅស៊ូទំហំ ១៨៦០ ហិកតា ចំការម្រេច៥០ហិកតា នៅអន្លង់វាប និងនៅថ្មដា ចំការកៅស៊ូនៅបឹងទន្លេម្រេច ខេត្តព្រះវិហារទំហំ ៣៣៧៦ហិកតា និងចំការម្រេច ៥០ ហិកតា ផងដែរ។

ទ្រី ភាព មានសិប្បកម្មកែច្នៃឈើពីរកន្លែងធំៗ ទីមួយ សារៈមន្ទីរក្រញូងនៅអង្គស្នួល ខេត្តកណ្ដាល និង មួយទៀត នៅសំរោង ស្រុកកណ្ដៀង ខេត្តពោធិសាត់។

---

[9] https://english.cambodiadaily.com/news/try-pheap-opens-motorcycle-assembly-plant-123764/

[10] https://thmeythmey.com/?page=detail&id=28860

[11] http://freshnewsasia.com/index.php/en/1928-2015-02-14-05-57-32.html

[12] https://www.phnompenhpost.com/business/plans-spilt-oil-refinery

មានផែស្ងួតចំនួន៣ ធំៗ ផែកុងតឺន័រនៅចោមចៅមួយកន្លែង មួយផែស្ងួតស្តុកឈើនៅភ្នំតូច ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ និងផែស្ងួតមួយទៀត នៅអូរយ៉ាដាវ ជាប់ព្រំដែនវៀតណាម។ ហើយ ទ្រី ភាពក៏មានតំបន់សេដ្ឋកិច្ចពិសេសចំនួន២ទៀតផងដែរ មួយនៅអូរយ៉ាដាវ ជាប់ព្រំដែនវៀតណាម និងមួយទៀតថ្មដា ជាប់ព្រំដែនថៃ ។

អាជីវកម្មប្រេងដែលដាក់ឈ្មោះ ថា ប៉ា ប៉ា ប៉េត្រូលៀម ដែលនាំចូលប្រេងពីប្រទេសថៃ សហការជាមួយក្រុមហ៊ុន PTT Global Chemical Plc បានបង្កើតតំបន់សេដ្ឋកិច្ចពិសេសថ្មីមួយទៀត មានទំហំទឹកប្រាក់ **៩00**លានដុល្លារ នៅទឹកឈូ ខេត្តកំពត ដែលរួមមានរោងចក្រចម្រាញ់ប្រេង និងកំពង់ផែនាំចូលប្រេងឆៅ លើផ្ទៃដីទំហំ ២៦៨ ហិកតា ដែលបានចំណាយទឹកប្រាក់ចំនួន ៣00 លានដុល្លារ ដើម្បីសាងសង់កំពង់ផែអន្តរជាតិមួយដ៏ធំនៅទីនោះ ដែលចុះអនុសារណៈ ជាមួយក្រុមហ៊ុនចិន **Hutchison Port Holdings Limited** មានមូលដ្ឋាននៅទីក្រុងហុងកុង នឹងចូលជ្រៅក្នុងសមុទ្រ៣គីឡូម៉ែត្រ ក្នុងជម្រៅ១៥ម៉ែត្រ ដែលអាចទទួលបានទំនិញចំនួន ២0 000 តោន បាន។

នៅឯអន្លង់វាបវិញ មហាជនក៏បានឃើញរោងចក្រអារឈើធំៗ ចំនួន២ ដែលយាមកាមយ៉ាងតឹងរ៉ឹង ដោយកំលាំងប្រដាប់អាវុធ នៅក្នុងចំការកៅស៊ូដីសម្បទានសេដ្ឋកិច្ចពិសេស MDS Import Export Co., Ltd រោងចក្រអារឈើដ៏ធំមួយឈ្មោះថា M-1 និងរោងចក្រអារឈើមួយទៀតឈ្មោះ M-2 រោងចក្រទាំងពីរនេះបានបិទទ្វារ និងដុតកាកសំណល់ដើម្បី បំបិទភស្តុតាង នាខែមេសា ២០១៩ បន្ទាប់ពីលេចលឺសូរដំណឹងថា មានការកាប់ និងដឹកជញ្ជូនឈើ ខ្នាតយក្ស កាលពីចុងឆ្នាំ ២០១៨ រហូតមក។ (រូបភាព រោងចក្រអារឈើ)









(ពិធីចុះអានុសារណៈយោគយល់គ្នា រវាងទ្រី ភាព គ្រុប ជាមួយក្រុមហ៊ុនចិន វិនិយោគផ្នែកប្រេង)



(ទ្រី ភាព និង ក្មួយប្រធានាធិបតីរុស្ស៊ី រ៉ូម៉ាន ពូទីន)



(ពិធីចុះអានុសារណៈយោគយល់គ្នា រវាងទ្រី ភាព គ្រប់ ជាមួយក្រុមហ៊ុនចិន វិនិយោកផ្នែកផលិតយាន
យន្តសំរាប់នាំចេញទំហំទឹកប្រាក់ ៥០លានដុល្លារ)




(ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ទិញ-លក់ រវាងក្រុមហ៊ុន ប៉ាប៉ា ភេត្រូលៀម (PAPA PETROLEUM Co.,Ltd) និងក្រុមហ៊ុន PTTGC (PTT GLOBAL CHEMICAL PUBLIC COMPANY LIMITED) នៅទីស្នាក់ការក្រុមហ៊ុន PTTGC ទីក្រុងបាងកក ប្រទេស កាពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦)



នាថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៦ នៅវិមានលំហែ ទ្រី ផាលែស ក្រុងកែប ខេត្តកែប ក្រុមហ៊ុន ទ្រី ភាព គ្រុប (កម្ពុជា) និង ក្រុមហ៊ុន HUTCHISON PORTS DEVELOPMENT LIMITED (HONG KONG) បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាលើគម្រោងវិនិយោគអភិវឌ្ឍន៍កំពង់ផែពហុវិស័យដែលមានទុនវិនិយោគប្រមាណជា ៣០០ លានដុល្លារអាមេរិក ដែលគម្រោងនេះគ្រោងនឹងបញ្ចប់ក្នុងចុងឆ្នាំ ២០១៩។[13]




ពិធីសម្ពោធជាផ្លូវការនៃម៉ាស៊ីនត្រជាក់ Hisense VRF Full DC Inverter ដោយមានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាង ក្រុមហ៊ុន ទ្រី ភាព គ្រុប និង ក្រុមហ៊ុន Sichuan Grand Royal Group Co., Ltd ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៦ នៅសណ្ឋាគារសុខាភ្នំពេញ លើទំហំវិនិយោគ ២០០លានយ័ន[14] ឬស្មើនឹង **US$28,229,846.00**

[13] https://www.facebook.com/trypheapgroup/photos/pcb.1036613213097619/1036611806431093/?type=3&theater
[14] http://www.grandroyalgroup.com/english/partner/air-conditioning/cambodia/




ពិធីចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នា (MOU) លើការទិញ-លក់ប្រេងឥន្ធនៈរវាងក្រុមហ៊ុន ប៉ាប៉ា ភេត្រូលៀម និង ក្រុមហ៊ុន AEC[15] នៅថ្ងៃទី 25 ខែ កុម្ភៈ ឆ្នាំ 2016។

[15] https://www.facebook.com/trypheapgroup/photos/pcb.976765005749107/976764415749166/?type=3&theater



(ក្រុមហ៊ុន ទ្រី ភាព ស៊ីញ៉ៅ អាជីវកម្មនាំចេញ ដំឡូងមី ជាមួយក្រុមហ៊ុន ថៃ)



TPG signed an agreement with Thailand’s Ubon Biro Ethanol (UBE)[16] to buy cassava in Cambodia for UBE’s refinery in Thailand’s Ubon Ratchathani province.

[16] https://www.khmertimeskh.com/32959/timber-exporter-shifts-into-cassava-with-new-jv/




**Try Pheap donated[17] US$ 2,100,000 to Red Cross in 2018**

[17] http://www.iic.edu.kh/event_detail.php?b3383bddd64d2d13cab7a40f3f4d1bc8=135




[18]

[18] http://www.iic.edu.kh/event_detail.php?b3383bddd64d2d13cab7a40f3f4d1bc8=135